# ៨~រឿង ចៅតប់ប្រមល់

កាលពីព្រេងនាយមានបុរសពីរនាក់ បានធ្វើការកុសលជាមួយគ្នា ។ លុះបុរសទាំងពីររំលាយខន្ធទៅ បុរសម្នាក់បានទៅកើតជាព្រះឥន្ទ្រ បុរសម្នាក់ទៀតទៅកើតជាបុរសកំសត់មានប្រពន្ធក្រលំបាកណាស់រកស៊ីនេសាទដាក់លបយកត្រី ជាអម្រស់អម្រចិញ្ចឹមជីវិត ។ គ្រាមួយ ព្រះឥន្ទ្របានបើកទិព្វចក្ខុទតមកឃើញបុរសនោះវេទនាលំបាកដូច្នោះ មានសេចក្ដីអាសូរករុណាវេលាយប់ព្រះឥន្ទ្រយកមាស ៣ ដុំ ទៅដាក់ក្នុងលបបុរសនោះ ។ លុះព្រឹកឡើងបុរសនោះទៅលើកលបមើលឃើញមាស មិនស្គាល់ជាមាស សំគាល់ថា ជាថ្មក៏ចោលទៅក្នុងទឹក ហើយដាក់លបទៅក្នុងទឹកវិញ ។ បុរសបានមកមើលលបទៀតគំរប់ ៣ ដង ។ ព្រះឥន្ទ្រយកមាសដាក់ក្នុងលបនោះដូចមុនទៀត ។ បុរសឃើញដូច្នោះនឹកខឹង ក៏ចងមាសទាំង៣ ដុំនោះពុនយកទៅធ្វើជាថ្មជើងក្រានដាំបាយ ។ ប្រពន្ធបុរសមិនស្គាល់មាស ក៏យកដុំមាសនោះទៅធ្វើថ្មជើងក្រានតាមបង្គាប់ប្ដី ។

ក្រោយនោះមានព្រះរាជបម្រើមកទារពន្ធព្រះរាជធានី មើលទៅឃើញដុំមាសដែលបុរសនោះធ្វើជាថ្មជើងក្រាន ក៏អោយបុរសនោះយកមាស ៣ ដុំ បង់ពន្ធដែលបុរសនោះជំពាក់រាជការ ។ បុរសនោះនឹកអរណាស់ ដោយខ្លួនទ័លក្រហើយព្រះរាជបម្រើយកដុំថ្មជើងក្រានដូច្នោះ ក៏ព្រមតាមបានប្រគល់ថ្មជើងក្រានទាំង៣ ដុំនោះទៅអោយព្រះរាជបម្រើភ្លាម ។ លុះព្រះរាជបម្រើបានដុំមាសពីបុរសនោះហើយក៏យក១ ដុំទៅថ្វាយព្រះមហាក្សត្រ ។ លុះទ្រង់សាកសួរពីហេតុដែលបានមាសមកនោះព្រះរាជបម្រើទូលតាមដំណើរ ។ ស្ដេចទ្រង់ជ្រាបថាបានមាសពីបុរសដូច្នោះទ្រង់អោយហៅបុរសនោះៗ ទៅដល់ទ្រង់សាកសួរទៀត ។ បុរសក្រាបទូលថា មាសរបស់ខ្លួន៣ ដុំបានជូនមកព្រះរាជបម្រើហើយ ។ ស្ដេចអោយទារយកមាស២ ដុំពីព្រះរាជបម្រើនោះ ហើយទ្រង់បង្គាប់អោយបុរសនោះរកមាសមកថ្វាយព្រះអង្គថែមទៀត ។ បុរសនោះក្រាបទូលថា "រកមាសទៀតពុំបានទេ" ។ ស្ដេចទ្រង់អោយយកបុរសនោះទៅឃុំ ។ ព្រឹកឡើងនាយតម្រួតដែលជាអ្នករក្សានេះ ប្រើធ្វើការដោយជេរស្ដីបុរសនោះ ។ លុះទ្រង់ជ្រាបដល់ស្ដេចៗទ្រង់អោយហៅបុរសនោះមកសួរពីហេតុធ្វើការឲ្យមានទាស់ចិត្តនាយតម្រួត ។ បុរសនោះក្រាបទូលថា "ទូលព្រះបង្គំមានសេចក្ដីតប់ប្រមល់នៅក្នុងខ្លួនខ្លាំងណាស់" ។ ស្ដេចក៏មានព្រះបន្ទូលថា "បើដូច្នោះត្រូវឯងរកសត្វតប់ប្រមល់នោះមកអោយអញ បើឯងរកពុំបានទេអញនឹងអោយពិឃាតឯងក្នុងគ្រានេះ" ។ បុរសឮដូច្នោះក៏ភិតភ័យគិតថា "មុខជាស្លាប់ហើយក្នុងគ្រានេះមិនដឹងជាទៅរកសត្វតប់ប្រមល់ឯណាទេ" តែមិនហ៊ានប្រកែកដោយខ្លាចអំណាចស្ដេច ក៏ក្រាបបង្គំលាស្ដេចដើរចេញទៅដោយបំណងថា នឹងដើរអោយស្លាប់ក្នុងព្រៃ លុះដើរចូលព្រៃឆ្ងាយទៅព្រះឥន្ទ្របើកព្រះនេត្រទិព្វមក ឃើញបុរសនោះមានសេចក្ដីវេទនាលំបាកដូច្នោះ ក៏និម្មិតជាអាស្រម១ នៅខាងមុខទី ដែលបុរសដើរទៅហើយព្រះឥន្ទ្រកាឡាខ្លួនធ្វើជាព្រះមហាឥសី ។ បុរសនោះមើលទៅឃើញអាស្រមដូច្នោះ ក៏មានចិត្តត្រេកអរ ដើរចូលទៅថ្វាយបង្គំឥសីក្នុងអាស្រមនោះ ។ ឥសីសួរបុរសនោះថា "ចៅមានហេតុអ្វី ?" ។ បុរសនោះទូលឥសីតាមដំណើរដែលស្ដេចអោយរកសត្វតប់ប្រមល់យកទៅថ្វាយនោះ ។ ឥសីថា "ចៅកុំព្រួយ" រួចឥសីបានយកបំពង់ពក១ មកសែកមន្តវិជ្ជាសិល្បសាស្ត្រកើតជាខ្លាសិង្ហដំរីពស់រមាសសុទ្ធតែជាសត្វសាហាវទាំងអស់ ហើយឥសីសែកជប់បង្រួញសត្វទាំងអស់នោះច្រកក្នុងបំពង់ពកប្រគល់បំពង់ពកនោះអោយទៅបុរសរួចផ្ដាំថា "អោយយកទៅថ្វាយស្ដេច ប៉ុន្តែមុននឹងបើកឆ្នុកនោះ អោយស្ដេចប្រមូលព្រះរាជវង្សានុវង្សមកជួបជុំហើយបិទទ្វាររាំងអោយជិតសិមបើកឆ្នុកមើល ព្រោះសត្វនោះរត់រហ័សណាស់" ។

លុះបុរសនោះទទួលបណ្ដាំឥសីស្រេចហើយ ក៏នាំយកសត្វនោះទៅថ្វាយស្ដេចក្រាបទូលថា "ទូលព្រះបង្គំរកសត្វតប់ប្រមល់បានហើយនៅក្នុងបំពង់ពកនោះ" ហើយក៏ទូលតាមដំណើរដែលឥសីផ្ដាំមក ។ ស្ដេចអោយប្រមូលព្រះរាជវង្សានុវង្សជួបជុំហើយទ្រង់ចាត់ការបិតទ្វារកំពែងរាំងស្រេច ទ្រង់អោយអាមាត្យបើកឆ្នុកបំពង់ពកនោះ ។ ខ្លាដំរីសិង្ហរមាសពស់ក៏ចេញពីក្នុងបំពង់មកខាំស្ដេចនឹងព្រះរាជវង្សានុវង្សនោះដល់នូវ

មរណភាពអស់ទៅ ។ ក្រោយនោះពួកអ្នកនគរបានឃើញបុរសនោះមានឫទ្ធានុភាពដូច្នោះ ក៏រៀបអភិសេកបុរសនោះអញ្ជើញឡើងសោយរាជ្យសម្បត្តិ ជាព្រះមហាក្សត្រក្នុងនគរនោះទៅ ។

សត្វទាំងឡាយក៏លាស្តេចបុរសនោះចូលទៅនៅព្រៃផ្តាំថា "បើស្តេចមានភ័យ ឬមានការអ្វីគ្រាន់តែមកដល់នឹងមកជួយយកអាសាជាជរាប" ។

## កម្លាំងអ្វីមិនស្មើកម្លាំងកម្ម